១៤១- លោក **ម៉េង ធុន្ធា** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៤២- លោក **ម៉ុន សុខេន** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៤៣- លោកស្រី **ឈិត្យ ឧស្សាហ៍** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៤៤- លោកស្រី **ស៊ឹម ឌីណា** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៤៥- លោក **កៅ វិសាល** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៤៦- លោក **ឆេង ចំរើន** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៤៧- លោក **ស៊ុន សុភា** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៤៨- លោក **អ៊ុត អំរិន** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៤៩- លោកស្រី **ជឹម មិដ្ឋនី** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៥០- លោក **អ៊ុន សុវណ្ណសាម** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៥១- លោក **អ៊ុក សេដ្ឋា** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៥២- លោក **ហែម ចំរ៉ុង** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៥៣- លោក **សេង សុគន្ធ** ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣
១៥៤- ឯកឧត្តម **ហ៊ុន សារឿន** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៥៥- លោក **ហេង សារិទ្ធ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៥៦- លោក **ឈួក ប៊ុណ្ណា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៥៧- លោក **គី មុនីរ័ត្ន** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៥៨- លោក **លីវ សុផាណ្ណារើន** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៥៩- លោក **អ៊ុច ប៊ុនុំ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៦០- លោក **ស៊ិន សារឿម** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៦១- លោក **ហ៊ុលគ្រង ផាណាង** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៦២- លោកស្រី **ឯក ចន្ទ្យចន្ទ្យនី** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤
១៦៣- លោក **ចណ្ណា វិទ្យា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៦៤- លោក **អ៊ូ សុជាតា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៦៥- លោកស្រី **សេង សុគន្ធារី** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៦៦- លោក **យស សុខេមរៈ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៦៧- លោកស្រី **ឡាយ ច័ន្ទរស្មី** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៦៨- លោក **កែន សុភារិទ្ធ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៦៩- លោក **ទុន ថុនា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧០- លោកស្រី **ឈឹម ថារីន** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧១- លោក **នៅ វណ្ណៈ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧២- លោក **កៃ អ៊ាងឆេង** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧៣- លោក **សុខ ឆា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧៤- លោក **ឥន្ទ ឡុងឌី** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧៥- លោក **ផល សុផេង** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧៦- លោក **ពៅ តារាឧឡ្យ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧៧- លោក **គឹម ធឿន** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧៨- លោកស្រី **ហេង ពិសី** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៧៩- លោកស្រី **ហ៊ុល ថុនណាក់** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨០- លោកស្រី **អ៊ុត អមរា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨១- លោក **យ៉ាន សាក់ណាតហៀ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨២- លោកស្រី **សួន លក្ខិណា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨៣- លោក **ឯក ចាន់សុខណា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨៤- លោក **ខែម រុយហ្សុន** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨៥- លោកស្រី **បាន បញ្ញារតន៍** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨៦- លោក **សាំង ទិច្ចមុនី** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨៧- លោក **យ៉ែម ណៃឆណារិទ្ធ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨៨- លោក **ជ សំផល** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៨៩- លោក **ឈយ គឹមសាន** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៩០- លោក **អ៊ឹង សារ៉ាឫទ្ធ** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៩១- លោក **ឌុច សុបញ្ញា** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

១៩២- លោក **ហាក់ គេអទី** ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១
មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៤ រោច ខែទុតិយាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥ សសរ

សេចក្ដីសម្រេច
ស្ដីពី
ការបង្កើតគណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤(ថ្មី) មាត្រា១០(ថ្មី) មាត្រា១១(ថ្មី) មាត្រា១២(ថ្មី) និងមាត្រា២០(ថ្មី) នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរ ឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- តាមសំណើរបស់រដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

សម្រេច

ប្រការ១.-

បង្កើតគណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមៈ

១. ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**	ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ	ប្រធាន
២. ឯកឧត្តមបណ្ឌិត **សន ពៅ**	អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ	អនុប្រធាន
៣. ឯកឧត្តមបណ្ឌិត **ជួរ គារី**	ប្រធានវិទ្យាស្ថានភាសាជាតិ	អនុប្រធាន
៤. ឯកឧត្តមកិត្តិបរិក្សបណ្ឌិត **គាត ឈន់**	ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងជាឧត្តមទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ	ទីប្រឹក្សា
៥. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**	រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ	ទីប្រឹក្សា
៦. ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**	ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ	ទីប្រឹក្សា
៧. ឯកឧត្តមបណ្ឌិតសភាចារ្យ **ថ្មុំ ម៉ល់**	ទីប្រឹក្សារាជរដ្ឋាភិបាល និងជាឧត្តមទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ	ទីប្រឹក្សា
៨. ឯកឧត្តម **សូ មុយឃៀង**	សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ	ទីប្រឹក្សា
៩. ឯកឧត្តមបណ្ឌិតសភាចារ្យ **សោម សុមុនី**	ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជាទទួលបន្ទុកជាប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ	សមាជិក
១០. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ	សមាជិក
១១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាឧត្តមទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ	សមាជិក
១២. ឯកឧត្តមបណ្ឌិត **យង់ ពៅ**	អគ្គលេខាធិការរាជបណ្ឌិត្យសភាកម្ពុជា	សមាជិក
១៣. ព្រះសុមេធវង្សបណ្ឌិត **សុខ ប៊ុនធឿន**	ប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និងក្រោយឧត្តមសិក្សានៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការ និងសាសនា និងជាព្រះចៅអធិការវត្តនន្ទមុនី	សមាជិក
១៤. ព្រះគ្រូចរណវិជ្ជា **ផល សុភឿន**	ព្រះសមុហ៍អនុគណខណ្ឌពោធិសែនជ័យ និងជាព្រះចៅអធិការវត្តព្រៃស្ពឺ	សមាជិក
១៥. ឯកឧត្តមបណ្ឌិត **ម៉ៅ សុភ្ជុន**	ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ	សមាជិក

១៦. លោក **ស សុខនី**	ប្រធាននាយកដ្ឋានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ និងសាសនា និងជា សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ	សមាជិក
១៧. លោកបណ្ឌិត **ខន្ធ មេខ**	អនុប្រធានវិទ្យាស្ថានភាសាជាតិ	សមាជិក
១៨. លោកបណ្ឌិត **ប៊ី សុខគង់**	ប្រធានផ្នែកភាសា និងភាសាវិទ្យា នៃវិទ្យាស្ថានភាសាជាតិ	សមាជិក
១៩. លោកបណ្ឌិត **ណុន សុខា**	ប្រធានផ្នែកអក្សរសាស្ត្រ និងអក្សរសិល្ប៍ នៃវិទ្យាស្ថានភាសាជាតិ	សមាជិក
២០. លោកស្រីបណ្ឌិត **គាវ ណារ៉ាង**	មន្ត្រីវិទ្យាស្ថានភាសាជាតិ	សមាជិកា
២១. លោកស្រីបណ្ឌិត **ហង់ ថាវី**	មន្ត្រីវិទ្យាស្ថានភាសាជាតិ	សមាជិកា
២២. លោកបណ្ឌិត **ជុំ ស៊ុនណារ៉ាង**	មន្ត្រីវិទ្យាស្ថានភាសាជាតិ	សមាជិក
២៣. លោក **គុយ រិន**	មន្ត្រីវិទ្យាស្ថានភាសាជាតិ	សមាជិក
២៤. លោកបណ្ឌិត **ឈិត វណ្ណាឫទ្ធិ**	អ្នកជំនាញប្រព័ន្ធទិន្នន័យ	សមាជិក
២៥. លោក **អុក ចួន**	សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ	សមាជិក
២៦. លោក **សឹង ផុស**	សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ	សមាជិក
២៧. លោក **យៀង វីរបុត្រ**	សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ	សមាជិក
២៨. លោកស្រី **កែប សុគន្ធាវតន៍**	សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ	សមាជិក
២៩. លោក **ចែម វត្ថុ**	មន្ត្រីអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៣០. លោក **លឹម លឿម**	គ្រូបង្រៀនភាសាបាលីពុទ្ធិកបឋមសិក្សាវត្តព្រៃស្អី ខណ្ឌពោធិ៍សែនជ័យ	សមាជិក។

ប្រការ២.-

សមាសភាពនៃគណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចដឹកនាំការប្រជុំដោយមានការប្រគល់សិទ្ធិពីប្រធាន។

ប្រការ៣.-

គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ មានភារកិច្ចរៀបចំធ្វើវចនានុក្រមភាសាខ្មែរ ដោយឈរលើស្មារតីអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ និងយកវចនានុក្រមខ្មែររៀបចំដោយសម្តេចព្រះសង្ឃរាជ **ជួន ណាត** ដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ ឆ្នាំ១៩៦៧ ជាគោល។

ប្រការ៤.-

គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងៗ ជាជំនួយការតាមការចាំបាច់។

ប្រការ៥.-

គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ អាចមានសិទ្ធិប្រើប្រាស់ថវិកាជាតិ រួមទាំងកញ្ចប់ថវិកាដោយឡែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល និងមានសិទ្ធិទទួលអំណោយនិងវិភាគទានពីដៃគូអភិវឌ្ឍន៍សហគមន៍ជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងពីសប្បុរសជននានា។

ប្រការ៦.-

សេចក្តីសម្រេចលេខ២៦ សសរ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០ កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
លេខ..០០៩៧......សហវ

សារាចរ
ស្តីពី
ការបង្កើត និងការគ្រប់គ្រងអាជីវកម្មអគារលក់ទំនិញរួចពន្ធ

កន្លងមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីណែនាំជាបន្តបន្ទាប់ សម្រាប់គ្រប់គ្រងបែបបទនាំចូល និងការលក់ទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធ ប៉ុន្តែដើម្បីឆ្លើយតបនឹងការរីកចម្រើនស្របតាមកាលានុវត្តភាព របស់ព្រះរាជាណាចក្រកម្ពុជាលើវិស័យពាក់ព័ន្ធ ជាពិសេសវិស័យទេសចរណ៍ ដែលបាននិងកំពុងចូលរួមចំណែកអភិវឌ្ឍ សង្គមនិងជំរុញកំណើនសេដ្ឋកិច្ច និងក្នុងគោលបំណងដើម្បីលើកកម្ពស់អនុលោមភាពនៃការអនុវត្តច្បាប់សម្រាប់អគារ លក់ទំនិញរួចពន្ធ ដោយអនុលោមតាមបញ្ញត្តិច្បាប់ជាតិ និងឧត្តមានុវត្តន៍អន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេច កែសម្រួលគោលការណ៍ និងនីតិវិធីមួយចំនួនក្នុងការបង្កើត ការគ្រប់គ្រង និងការត្រួតពិនិត្យការនាំចូលនាំចេញ ការចរាចរ ការដឹកជញ្ជូន ការសន្និធិ និងការលក់ទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធ ដូចខាងក្រោម÷

I- គោលការណ៍ផ្តល់អាជ្ញាបណ្ណអាជីវកម្ម

១- ធុរជនត្រូវស្នើសុំទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាតាមទម្រង់កំណត់ ដោយភ្ជាប់ជាមួយនូវគម្រោងប្លង់សំណង់លម្អិត និងទីតាំងដែលត្រូវសាងសង់ភណ្ឌាគារ។ សំណើសុំត្រូវមានប្រសិទ្ធភាពសេដ្ឋកិច្ច។

២- ធុរជនត្រូវមានលិខិតថ្កោលទោសដែលចេញដោយស្ថាប័នមានសមត្ថកិច្ច។

៣- ធុរជនត្រូវមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីផ្តល់នូវទីកន្លែង សម្ភារៈបរិក្ខារ បុគ្គលិក និងសេវាកម្មចាំបាច់សម្រាប់កិច្ចដំណើរការអាជីវកម្ម។

៤- ធុរជនត្រូវមានប្រវត្តិអនុលោមភាពលើកាតព្វកិច្ចសារពើពន្ធស្អាតស្អំ រាប់បញ្ចូលទាំងការបំពេញកាតព្វកិច្ចពន្ធអាករ ការគ្រប់គ្រង ថែរក្សា កាន់កាប់ឯកសារនាំចេញនាំចូល និងបញ្ជីគណនេយ្យត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន។

៥- អាជ្ញាបណ្ណអាជីវកម្មអគារលក់ទំនិញរួចពន្ធត្រូវកំណត់នូវលក្ខខណ្ឌនៃកិច្ចសន្យា និងប្រតិបត្តិការធុរកិច្ចរវាងរដ្ឋបាលគយ និងប្រតិបត្តិករអគារលក់ទំនិញរួចពន្ធ។

៦- អាជ្ញាបណ្ណអាជីវកម្មអគារលក់ទំនិញរួចពន្ធមិនអនុញ្ញាតឱ្យលក់ ឬផ្ទេរទៅភាគីផ្សេងឡើយ។

II- ប្រភេទអគារលក់ទំនិញរួចពន្ធ

១- ច្រកចេញដំណើរអន្តរជាតិ÷ មានទីតាំងនៅតាមអាកាសយានដ្ឋានអន្តរជាតិ កំពង់ផែអន្តរជាតិ មាត់ច្រកព្រំដែនអន្តរជាតិផ្លូវគោក និងផ្លូវដែក ហើយត្រូវស្ថិតនៅខាងក្រោយបញ្ជរត្រួតពិនិត្យអន្តោប្រវេសន៍។

២- ច្រកអ្នកដំណើរមកដល់÷ មានទីតាំងនៅតាមអាកាសយានដ្ឋានអន្តរជាតិ កំពង់ផែអន្តរជាតិ មាត់ច្រកព្រំដែនអន្តរជាតិផ្លូវគោក និងផ្លូវដែក ហើយត្រូវស្ថិតនៅខាងមុខបញ្ជរត្រួតពិនិត្យរបស់រដ្ឋបាលគយ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

៣- ទីប្រជុំជន (Downtown Duty Free Shop)÷ មានទីតាំងនៅផ្ទៃក្នុងប្រទេស សម្រាប់លក់ទំនិញជូនបុគ្គលរង់ចាំការចេញដំណើរអន្តរជាតិ មន្ត្រីការទូត ឬបុគ្គលមានបុព្វសិទ្ធិប្រហាក់ប្រហែល និងបុគ្គលផ្សេងទៀតដែលទទួលបានការអនុគ្រោះដោយឡែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤- នៅលើយន្តហោះ ឬនាវាធ្វើដំណើរអន្តរជាតិ។

III- គោលការណ៍អនុវត្តសម្រាប់ការនាំចូលទំនិញ និងបែបបទនាំចូល

១- កំណត់បរិមាណ និងមុខទំនិញអនុញ្ញាតឱ្យនាំចូលសម្រាប់អគារលក់ទំនិញរួចពន្ធប្រចាំខែនីមួយៗ ស្របតាមតារាងឧបសម្ព័ន្ធនៃសារាចរនេះ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចពិនិត្យនិងសម្រេចលើកលែងការកំណត់បរិមាណទំនិញនាំចូលនេះ ក្នុងករណីពិនិត្យឃើញថា ប្រតិបត្តិករអគារលក់ទំនិញរួចពន្ធដែលស្នើសុំមានកម្រិតអនុលោមភាពច្បាប់ខ្ពស់។

២- ត្រូវមានលិខិតអនុញ្ញាតនាំចូល ផ្តល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៅរាល់ពេលនាំចូល។

៣- រាល់ទំនិញនាំចូលក្រោមរបបអគារលក់ទំនិញរួចពន្ធ ត្រូវបង់កម្រៃក្នុងអត្រា ១០%។

៤- ការបំពេញបែបបទនាំចូល និងបង់កម្រៃ ត្រូវធ្វើនៅតាមបណ្តាសាខា ឬការិយាល័យគយនិងរដ្ឋាករមាត់ច្រកនាំចូលតាមច្បាប់ និងនីតិវិធីជាធរមាន។

IV- ឃ្លាំងទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធ

១- ត្រូវមានភណ្ឌាគារ(ឃ្លាំងសន្និធិទំនិញ)ដាច់ដោយឡែក សម្រាប់តែទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធប៉ុណ្ណោះ ហើយត្រូវមានសោពីរ ដែលមួយសម្រាប់រដ្ឋបាលគយ និងមួយទៀតសម្រាប់ម្ចាស់អគារលក់ទំនិញរួចពន្ធ។

២- ត្រូវបំពាក់មធ្យោបាយលើកដាក់និងត្រួតពិនិត្យទំនិញឱ្យបានគ្រប់គ្រាន់ សម្រាប់បម្រើឱ្យប្រតិបត្តិការលើកដាក់ផ្ទេរ ផ្ទុក ត្រួតពិនិត្យ។ល។

៣- ត្រូវមានរបាំងចល័តសម្រាប់ចែកឱ្យដាច់នូវមុខទំនិញដែលស្ថិតក្រោមការត្រួតពិនិត្យរបស់គយ និង/ឬក្នុងគោលបំណងដើម្បីសម្រួលដល់ការកំណត់មុខសញ្ញាទំនិញពីមួយទៅមួយ។

៤- ត្រូវមានស្លាក និងសញ្ញាសម្គាល់ផ្សេងៗសម្រាប់សម្គាល់តាមឡូតិ៍នីមួយៗ ជាប្លុក និងជាថ្នាក់នៅក្នុងភណ្ឌាគារ។

V- ការចរាចរដឹកជញ្ជូនទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធ

១- រាល់ការចរាចរដឹកជញ្ជូនទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធឆ្លងកាត់ផ្ទៃក្នុងប្រទេស ត្រូវអមភ្ជាប់ជាមួយនូវលិខិតអនុញ្ញាតដឹកជញ្ជូន ដែលផ្តល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ក្នុងករណីដែលអង្គភាពគយនិងរដ្ឋាករមានសមត្ថកិច្ចយល់ថាចាំបាច់ ត្រូវចាត់មន្ត្រីគយនិងរដ្ឋាករយ៉ាងតិចពីររូបអមឃ្លាំមើលទំនិញទាំងនោះ រហូតដល់គោលដៅអាជីវកម្មស្របច្បាប់នានា។

២- ត្រូវមានរថយន្តឃ្លុបបិទជិត និងធានាសុវត្ថិភាពត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដោយមានទ្វារតែមួយសម្រាប់បិទត្រាសៀលគយ។

៣- រថយន្តដឹកជញ្ជូនទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធ ត្រូវបាញ់ភ្ជាប់ពាណិជ្ជសញ្ញាក្រុមហ៊ុន និងមានបណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូនបិទលើកញ្ចក់រថយន្តផ្នែកខាងមុខ ដែលផ្តល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

VI- **អតិថិជនរបស់អគារលក់ទំនិញរួចពន្ធ**

អតិថិជនអគារលក់ទំនិញរួចពន្ធរួមមាន ភ្ញៀវបរទេស នាវិកបរទេស មន្ត្រីស្ថានទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបុគ្គលផ្សេងទៀតដែលទទួលបានការអនុគ្រោះដោយឡែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមលក្ខខណ្ឌនៃការលក់ទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធ។

VII- **លក្ខខណ្ឌនៃការលក់ទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធ**

១- ទំនិញត្រូវបានអនុញ្ញាតលក់ជូនអ្នកដំណើរមកដល់ អ្នកដំណើរចេញពីព្រះរាជាណាចក្រកម្ពុជា ឬអ្នកដំណើរឆ្លងកាត់ក្រោមបញ្ញត្តិនៃសារាចរនេះ នៅពេលដែលអ្នកដំណើរបានបង្ហាញលិខិតឆ្លងដែនដែលមានសុពលភាព និងបានត្រួតពិនិត្យដោយអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការអនុញ្ញាតឱ្យចូល ឬចាកចេញពីព្រះរាជាណាចក្រកម្ពុជា។

២- ទំនិញត្រូវបានអនុញ្ញាតឱ្យលក់ដោយផ្ទាល់ដល់អ្នកដំណើរនៅលើជើងហោះហើរអន្តរជាតិ របស់អាកាសចរណ៍កម្ពុជា ឬអាកាសចរណ៍ដទៃទៀត ឬអ្នកដំណើរតាមនាវាអន្តរជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

៣- អតិថិជនជាភ្ញៀវបរទេស អនិកជនកម្ពុជា និងប្រជាជនកម្ពុជាដែលរង់ចាំចេញដំណើរអន្តរជាតិ ត្រូវបង្ហាញលិខិតឆ្លងដែនដែលមានសុពលភាព ដោយភ្ជាប់ជាមួយនូវសំបុត្រយន្តហោះដែលមានកំណត់ពេលវេលានៃការចេញដំណើរមិនលើសរយៈពេល១៥ថ្ងៃ សម្រាប់បម្រើឱ្យការទិញទំនិញនៅអគារលក់ទំនិញរួចពន្ធប្រភេទទីប្រជុំជន។ រាល់ទំនិញទាំងអស់ត្រូវប្រគល់ជូនអតិថិជននៅមាត់ច្រកអន្តរជាតិ នៅពេលដែលនីតិវិធីនៃការធ្វើដំណើរចេញត្រូវបានបញ្ចប់ លើកលែងតែមានការអនុញ្ញាតដោយឡែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤- រូបិយបណ្ណបរទេសសម្រាប់ប្រើប្រាស់ក្នុងការទូទាត់ទំនិញ ត្រូវអនុលោមតាមអត្រាប្តូរប្រាក់ដែលប្រកាសឱ្យប្រើដោយធនាគារជាតិនៃកម្ពុជា។

VIII - **ប្រភេទទំនិញសម្រាប់លក់នៅអគារលក់ទំនិញរួចពន្ធ**

១- ប្រភេទទំនិញសម្រាប់លក់នៅអគារលក់ទំនិញរួចពន្ធ រួមមានទំនិញនាំចូលដែលមានចែងក្នុងតារាងឧបសម្ព័ន្ធស្តីពីបរិមាណ និងមុខទំនិញអនុញ្ញាតឱ្យនាំចូលសម្រាប់អគារលក់ទំនិញរួចពន្ធប្រចាំខែនីមួយៗ នៃសារាចរនេះ ឬទំនិញដែលមានការអនុញ្ញាតដោយឡែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- អគារលក់ទំនិញរួចពន្ធត្រូវបានលើកទឹកចិត្តឱ្យដាក់លក់ទំនិញផលិតក្នុងស្រុក និងទំនិញដែលមានប្រភពស្របច្បាប់ដទៃទៀតតាមបទប្បញ្ញត្តិជាធរមាន។ ទំនិញនាំចូលក្រោមរបបអគារលក់ទំនិញរួចពន្ធ ទំនិញផលិតក្នុងស្រុក ឬទំនិញមានប្រភពស្របច្បាប់ដទៃទៀតដែលលក់នៅអគារលក់ទំនិញរួចពន្ធ ត្រូវបានចាត់ទុកជាទំនិញនាំចេញ និងទទួលបានការលើកទឹកចិត្តតាមបទប្បញ្ញត្តិជាធរមាន។ ប្រតិបត្តិករអគារលក់ទំនិញរួចពន្ធត្រូវរាយការណ៍ជូនរដ្ឋបាលគយឱ្យបានច្បាស់លាស់នូវបញ្ជីមុខទំនិញផលិតក្នុងស្រុក ឬទំនិញមានប្រភពស្របច្បាប់ដទៃទៀតដែលត្រូវដាក់តាំងលក់។

៣- រាល់ទំនិញដាក់តាំងលក់នៅអគារលក់ទំនិញរួចពន្ធត្រូវបោះត្រា "CAMBODIA DUTY NOT PAID" តាមគំរូកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

IX- បរិមាណកំណត់ក្នុងការលក់ទំនិញ

១- អ្នកធ្វើដំណើរមកដល់ព្រះរាជាណាចក្រកម្ពុជា អាចទិញទំនិញក្នុងបរិមាណកំណត់ដូចមានក្នុងតារាងឧបសម្ព័ន្ធស្តីពីបរិមាណ និងមុខទំនិញអនុញ្ញាតឱ្យលក់ជូនអតិថិជនម្នាក់នៃអគារលក់ទំនិញរួចពន្ធ នៃសារាចរនេះ។

២- អ្នកធ្វើដំណើរចេញពីព្រះរាជាណាចក្រកម្ពុជា អាចទិញទំនិញក្នុងបរិមាណមិនកំណត់ ប៉ុន្តែអ្នកដំណើរត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះរាល់នីតិវិធី និងបរិមាណកំណត់សម្រាប់នាំចូលទំនិញនៅប្រទេសគម្យដ្ឋាន។

៣- អតិថិជនអាចទិញទំនិញនៅអគារលក់ទំនិញរួចពន្ធប្រភេទទីប្រជុំជន ក្នុងបរិមាណមិនកំណត់ ដោយការប្រគល់ទំនិញត្រូវធ្វើឡើងនៅមាត់ច្រកព្រំដែនអន្តរជាតិណាមួយនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលគយ លើកលែងតែទំនិញដែលមានបរិមាណសមស្របសម្រាប់អ្នកដំណើរ និងការប្រើប្រាស់ផ្ទាល់ខ្លួនតាមបទប្បញ្ញត្តិជាធរមាន ដែលទទួលបានការអនុញ្ញាតដោយឡែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យសម្របសម្រួលប្រគល់ទទួលនៅនឹងកន្លែងអាជីវកម្មដ្ឋាន។

X- ការនាំចេញទៅវិញ ការបង្វែរលក់នៅទីផ្សារក្នុងស្រុក និងការទទួលខុសត្រូវលើទំនិញដែលបាក់បែក ខូចខាត និង/ឬខូចគុណភាព

១- ប្រសិនបើទំនិញបាននាំចូលក្រោមរបបអគារលក់ទំនិញរួចពន្ធ ស្ថិតក្នុងសន្និធិលើសកាលកំណត់ ដោយសារការលក់មិនចេញ ហើយចាំបាច់ត្រូវបំផ្លាញចោល បញ្ចេញលក់នៅទីផ្សារក្នុងស្រុក ឬត្រូវនាំចេញទៅវិញ ប្រតិបត្តិករអគារលក់ទំនិញរួចពន្ធ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយតាមបទប្បញ្ញត្តិជាធរមាន។

២- ទំនិញដែលត្រូវបញ្ចេញលក់នៅទីផ្សារក្នុងស្រុក ត្រូវជាប់កាតព្វកិច្ចពន្ធនិងអាករតាមបទប្បញ្ញត្តិជាធរមាន។

៣- ទំនិញដែលបាក់បែក ខូចខាត និង/ឬខូចគុណភាពពុំអាចលក់សម្រាប់ប្រើប្រាស់បាន ប្រតិបត្តិករអគារលក់ទំនិញរួចពន្ធត្រូវធ្វើការកត់ត្រាដោយមានការបញ្ជាក់ទទួលស្គាល់ពីមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច សម្រាប់ប្រើប្រាស់ជាឯកសារយោង ដើម្បីស្នើសុំបំផ្លាញចោល។

XI- ភារកិច្ចរបស់មន្ត្រីគយនិងរដ្ឋាករ

១- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចាត់តាំងមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចពាក់ព័ន្ធក្នុងចំនួនសមស្របប្រចាំការនៅតាមភណ្ឌាគារ និងអគារលក់ទំនិញរួចពន្ធ ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យរាល់ការបញ្ចេញបញ្ចូលទំនិញ ការលក់ទំនិញ និងរាយការណ៍ជាប្រចាំពីសកម្មភាពនេះជូនអង្គភាពសាមី ហើយក៏ត្រូវចាត់តាំងផងដែរនូវមន្ត្រីគយនិងរដ្ឋាករសម្រាប់បម្រើឱ្យការឃ្លាំមើលនៅតាមបណ្តាមូលដ្ឋាននានា ដែលសង្ស័យថាមានសកម្មភាពមិនប្រក្រតីពាក់ព័ន្ធនឹងចរាចរដឹកជញ្ជូនទំនិញក្រោមរបបអគារលក់ទំនិញរួចពន្ធ។ ករណីចាំបាច់ក្នុងការទប់ស្កាត់ ឬបង្ក្រាប ត្រូវសហការជាមួយមន្ត្រីគយនិងរដ្ឋាករនៃនាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស ឬសាខាគយនិងរដ្ឋាកររាជធានីខេត្ត ឬត្រូវស្នើសុំកិច្ចសហការពីអាជ្ញាធរមានសមត្ថកិច្ច ដែលមានទីតាំងជិតបំផុតនៃទីកន្លែងកើតហេតុតាមបទប្បញ្ញត្តិជាធរមាន។

២- មន្ត្រីគយនិងរដ្ឋាករគ្រប់ផ្នែក ទាំងនៅតាមភណ្ឌាគារ អគារលក់ទំនិញរួចពន្ធ ឬបណ្តាមូលដ្ឋាននានា មិនត្រូវបង្កភាពអសកម្ម និងការយឺតយ៉ាវខុសពីនីតិវិធីឡើយ។ បើពុំដូច្នេះទេ នឹងត្រូវរងនូវការពិន័យតាមបទប្បញ្ញត្តិជាធរមាន។

XII- ភារកិច្ចរបស់ប្រតិបត្តិករអគារលក់ទំនិញរួចពន្ធ

១- គោរព និងអនុវត្តឱ្យបានហ្មត់ចត់តាមខ្លឹមសារនៃសារាចរនេះ កិច្ចសន្យាស្ដីពីការបង្កើតនិងធ្វើអាជីវកម្មអគារលក់ទំនិញរួចពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត។

២- បង្កការងាយស្រួល និងសហការជាប់ជាប្រចាំជាមួយមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ។

៣- ធ្វើរបាយការណ៍ឱ្យបានទាន់ពេលវេលាតាមគំរូដែលណែនាំដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

៤- កត់ត្រាឱ្យបានច្បាស់លាស់លើវិក្កយបត្រលក់ នូវយថាប្រភេទ បរិមាណទំនិញ ព្រមទាំងអត្តសញ្ញាណអតិថិជនប្រចាំថ្ងៃនីមួយៗ។

៥- រក្សាទុកនូវទិន្នន័យរបស់អតិថិជនសម្រាប់ការជម្រះបញ្ជិកាគយ។

៦- ទទួលខុសត្រូវចំពោះមុខច្បាប់ នូវការជ្រាបចេញទំនិញនាំចូលក្រោមរបបអគារលក់ទំនិញរួចពន្ធមកទីផ្សារក្នុងស្រុក។

៧- បង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំ តាមបទប្បញ្ញត្តិជាធរមាន។

XIII- ការទទួលខុសត្រូវលើការរំលោភបំពាន

ប្រតិបត្តិករអគារលក់ទំនិញរួចពន្ធណាដែលរំលោភបំពានបញ្ញត្តិនៃសារាចរនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ នឹងត្រូវព្យួរអាជ្ញាបណ្ណអាជីវកម្មជាបណ្ដោះអាសន្ន ឬដកអាជ្ញាបណ្ណអាជីវកម្ម ព្រមទាំងអាចទទួលរងនូវទោសទណ្ឌតាមច្បាប់ជាធរមាន។

ទទួលបានសារាចរនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវចាត់ចែងផ្សព្វផ្សាយឱ្យបានទូលាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

ថ្ងៃពុធ ១៣កើត ខែអាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៨

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល÷

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្ដម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- សភាពាណិជ្ជកម្មកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ

ស្តីពី

បរិមាណ និងមុខទំនិញអនុញ្ញាតឱ្យនាំចូលសម្រាប់អគាររលក់ទំនិញរួចពន្ធប្រចាំខែនីមួយៗ

(អមសារាចរលេខ០០៧ សហវ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

ល.រ	មុខទំនិញ	ឯកតា	បរិមាណ	សេចក្តីផ្សេងៗ
១	បារី	កាតុង៥០សុង	200	
២	បារីស៊ីហ្គា	ប្រអប់តូច	300	
៣	ស្រា	កេស	200	
៤	ស្រាបៀរ	កេស	450	
៥	ភេសជ្ជៈផ្សេងទៀត	កេស	450	
៦	នំគ្រប់ប្រភេទ	គីឡូក្រាម	1,000	
៧	ស្ករគ្រាប់គ្រប់ប្រភេទ	គីឡូក្រាម	1,000	
៨	ចំណីអាហារកំប៉ុង	គីឡូក្រាម	600	
៩	កាហ្វេ-តែកញ្ចប់ ឬ កំប៉ុង	គីឡូក្រាម	300	
១០	សំលៀកបំពាក់	រាយ	300	
១១	ប៊ូចងសក់	រាយ	900	
១២	កន្សែងគ្រប់ប្រភេទ	រាយ	600	
១៣	ក្រវ៉ាត់ក	រាយ	300	
១៤	ស្បែកជើង	គូ	300	
១៥	ស្រោមជើង	គូ	300	
១៦	ខ្សែក្រវ៉ាត់	រាយ	300	
១៧	កាបូប	រាយ	150	
១៨	គ្រឿងសំអាងផ្សេងៗ	រាយ	1,200	
១៩	ទឹកអប់	ដប	300	
២០	សំភារៈកីឡា	រាយ	300	
២១	ប្រដាប់ក្មេងលេង	រាយ	600	
២២	វត្ថុអនុស្សាវរីយ៍	រាយ	600	
២៣	ឆ័ត្រ	រាយ	300	
២៤	មួក	រាយ	300	
២៥	នាឡិកា	រាយ	150	

ល.រ	មុខទំនិញ	ឯកតា	បរិមាណ	សេចក្ដីផ្សេងៗ
២៦	ប៊ិច ស្លាបប៉ាកា	រាយ	300	
២៧	ដែកកេះ	រាយ	900	
២៨	ម៉ាស៊ីនថតរូបតូចជាលក្ខណៈឯកជន	គ្រឿង	90	
២៩	ម៉ាស៊ីនគិតលេខ	គ្រឿង	90	
៣០	ម៉ាស៊ីនថតវីដេអូតូចជាលក្ខណៈឯកជន	គ្រឿង	60	
៣១	កូនវិទ្យុ	គ្រឿង	90	
៣២	ម៉ាញេតូហ្វូនក្រោម ៥0W	គ្រឿង	60	
៣៣	គ្រឿងអគ្គិសនីតូចៗផ្សេងទៀត	គ្រឿង	300	
៣៤	ទៀន	គីឡូក្រាម	500	
៣៥	គ្រឿងអលង្ការកាឡៃ	រាយ	300	
៣៦	គ្រឿងអលង្ការ	រាយ	300	
៣៧	វ៉ែនតា	រាយ	300	
៣៨	ផលិតផលទឹកដោះគោ	គីឡូក្រាម	1,000	
៣៩	វ៉ាលីគ្រប់ប្រភេទ	រាយ	300	
៤០	ផលិតផលអេឡិកត្រូនិចតូចៗ	រាយ	200	
៤១	ផលិតផលគ្រឿងស្គាល់តូចៗ	រាយ	500	
៤២	អាហារបំប៉ន	គីឡូក្រាម	200	
៤៣	ដំណាប់/ផ្លែឈើក្រៀម	គីឡូក្រាម	1,000	
៤៤	សម្ភារៈជំនួយការធ្វើដំណើរ (សោ ក្រណាត់បាំងភ្នែក ខ្នើយ ភួយ...)	រាយ	500	

តារាងឧបសម្ព័ន្ធ

ស្តីពី

បរិមាណ និងមុខទំនិញអនុញ្ញាតឱ្យលក់ជូនអតិថិជនមួយនាក់នៃអគារលក់ទំនិញរួចពន្ធ

(អមសារាចរលេខ ០០៧ សហវ.ទ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

ល.រ	មុខទំនិញ	ឯកតា	បរិមាណ	សេចក្តីផ្សេងៗ
១	បារី	ស៊ុង	2	
២	បារីស៊ីហ្គា	ប្រអប់តូច	5	
៣	ស្រា	ដប	2	
៤	ស្រាបៀរ	កំប៉ុង	6	
៥	ភេសជ្ជៈផ្សេងទៀត	កំប៉ុង	6	
៦	នំគ្រប់ប្រភេទ	គីឡូក្រាម	1	
៧	ស្ករគ្រាប់គ្រប់ប្រភេទ	គីឡូក្រាម	1	
៨	ចំណីអាហារកំប៉ុង	គីឡូក្រាម	1	
៩	កាហ្វេ-តែកញ្ចប់ ឬ កំប៉ុង	គីឡូក្រាម	1	
១០	សំលៀកបំពាក់	រាយ	2	
១១	បូចងសក់	រាយ	2	
១២	កន្សែងគ្រប់ប្រភេទ	រាយ	2	
១៣	ក្រវាត់ក	រាយ	2	
១៤	ស្បែកជើង	គូ	2	
១៥	ស្រោមជើង	គូ	2	
១៦	ខ្សែក្រវាត់	រាយ	2	
១៧	កាបូប	រាយ	2	
១៨	គ្រឿងសំអាងផ្សេងៗ	រាយ	2	
១៩	ទឹកអប់	ដប	2	
២០	សំភារៈកីឡា	រាយ	2	
២១	ប្រដាប់ក្មេងលេង	រាយ	5	
២២	វត្ថុអនុស្សាវរីយ៍	រាយ	5	
២៣	ឆ័ត្រ	រាយ	2	
២៤	មួក	រាយ	2	
២៥	នាឡិកា	រាយ	2	

ល.រ	មុខទំនិញ	ឯកតា	បរិមាណ	សេចក្តីផ្សេងៗ
២៦	ប៊ិច ស្លាបប៉ាកា	រាយ	2	
២៧	ដែកកេះ	រាយ	2	
២៨	ម៉ាស៊ីនថតរូបតូចជាលក្ខណៈឯកជន	គ្រឿង	1	
២៩	ម៉ាស៊ីនគិតលេខ	គ្រឿង	1	
៣០	ម៉ាស៊ីនថតវីដេអូតូចជាលក្ខណៈឯកជន	គ្រឿង	1	
៣១	កូនវិទ្យុ	គ្រឿង	1	
៣២	ម៉ាញេតូហ្វូនក្រោម ៥០W	គ្រឿង	1	
៣៣	គ្រឿងអគ្គិសនីតូចៗផ្សេងទៀត	គ្រឿង	2	
៣៤	ទៀន	រាយ	5	
៣៥	គ្រឿងអលង្ការកាឡៃ	រាយ	2	
៣៦	គ្រឿងអលង្ការ	រាយ	2	
៣៧	វ៉ែនតា	រាយ	2	
៣៨	ផលិតផលទឹកដោះគោ	រាយ	5	
៣៩	វ៉ាលីគ្រប់ប្រភេទ	រាយ	1	
៤០	ផលិតផលអេឡិកត្រូនិចតូចៗ	រាយ	1	
៤១	ផលិតផលគ្រឿស្គាល់តូចៗ	រាយ	2	
៤២	អាហារបំប៉ន	រាយ	2	
៤៣	ដំណាប់/ផ្លែឈើក្រៀម	គីឡូក្រាម	1	
៤៤	សម្ភារៈជំនួយការធ្វើដំណើរ (សោ ក្រណាត់បាំងភ្នែក ខ្នើយ ភួយ...)	រាយ	2	

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ៩៧១ ឧស្ស.ស្ក/ប្រកក

ថ្ងៃ សុក្រ ១៤កើត ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៨

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១

ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រកែច្នៃជ័រកៅស៊ូ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ របស់ក្រុមហ៊ុន វៀតណាម (កម្ពុជា) អ៊ីខននើមី ត្រេដ អេន អ៊ិនដាសស្ទ្រី ខមកេនី លីមីធីត (វីខេតធី)

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន វៀតណាម (កម្ពុជា) អ៊ីខននើមី ត្រេដ អេន អ៊ិនដាសស្ទ្រី ខមកេនី លីមីធីត (វីខេតធី) (VIETNAM (KAMPUCHEA) ECONOMY TRADE AND INDUSTRY COMPANY LIMITED (VKETI) CO., LTD.) តំណាងដោយ លោក **PHAM TRONG NHON** បង្កើតរោងចក្រកែច្នៃជ័រកៅស៊ូ ដែលមានទីតាំងស្ថិតនៅ ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
ជ័រកៅស៊ូ (កែច្នៃ)	២២១៩

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖ " រោងចក្រកែច្នៃជ័រកៅស៊ូ វៀតណាម (កម្ពុជា) អ៊ីខននើមី ត្រេដ អេន អ៊ិនដាសស្ទ្រី ខមភេនី លីមីធីត (វីខេតធី) "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់ហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តក្រចេះ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលាខេត្តក្រចេះ
- -មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តក្រចេះ
- -រដ្ឋបាលស្រុកស្នួល
- -រដ្ឋបាលឃុំឃ្សឹម
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ស៊ូវ ហ្គូដ ហ្គាម៉ិន ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូវ ហ្គូដ ហ្គាម៉ិន ឯ.ក (SEW GOOD GARMENT CO., LTD.) តំណាងដោយលោក **ZHOU, ZIGEN** បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ូវ ហ្វួដ ហ្គាម៉ិន ឯ.ក "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់ហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលារាជធានីភ្នំពេញ
- -មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ
- -រដ្ឋបាលខណ្ឌពោធិ៍សែនជ័យ
- -រដ្ឋបាលសង្កាត់កន្ទោក
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

12

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី